**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ

ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃដាក់ : ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤

ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា

ភាសាដើម : អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Oct-2014, 14:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# សំណើរបស់សហព្រះរាជអាជ្ញាសុំចាត់តាំងក្រុមមេធាវីការពារក្ដី *ដែលជាមិត្តរបស់តុលាការ* និងពន្លឿនកិច្ចដំណើរការនីតិវិធីសវនាការ

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្ដារា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្ដីជនជាប់ចោទ**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

# I. សេចក្តីផ្តើម និង ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ នៅពាក់កណ្តាលកិច្ចដំណើរការនីតិវិធី ក្រុមមេធាវីការពារក្តី នួន ជា និង ខៀវ សំផន គឺលោក សុន អរុណ, លោក Victor Koppe, លោក គង់ សំអុន និងលោកស្រី Anta Guissé បានដកខ្លួនចេញពីបន្ទប់សវនាការធំរបស់ អ.វ.ត.ក ដោយពុំមានការអនុញ្ញាតពីអង្គជំនុំជម្រះ។ នៅមុនការចាកចេញនេះ ពួកគាត់បានបញ្ជាក់ថាពួកគាត់នឹងមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនាពេលក្រោយៗទៀតទេ ល្គឹកណាតែអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ ដើម្បីឆ្លើយតបទៅតាមការទាមទាររបស់ពួកគាត់[1]។

២. នួន ជា និង ខៀវ សំផន ម្នាក់ៗបានបញ្ជាក់រឿងនេះយ៉ាងច្បាស់នៅក្នុងកំណត់សម្គាល់ផ្ទាល់មាត់របស់ពួកគាត់រៀងៗខ្លួន មុននឹងក្រុមមេធាវីការពារក្តីរបស់ពួកគាត់ចាកចេញពីបន្ទប់សវនាការថា ពួកគាត់បានណែនាំឲ្យមេធាវីការពារក្តីរបស់ពួកគាត់ មិនឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការបើការទាមទាររបស់ពួកគាត់សុំឲ្យមានការផ្អាកនោះមិនត្រូវបានធ្វើតាមទេ។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានបញ្ជាក់ផងដែរថា ពួកគាត់ត្រូវចាកចេញទៅតាមការណែនាំរបស់កូនក្តីគាត់[2]។

៣. ការទាមទាររបស់ ខៀវ សំផន និងការទាមទាររបស់ នួន ជា គឺមានលក្ខណៈខុសគ្នា។ នួន ជា បានស្វែងរកនូវសេចក្តីសម្រេចមួយលើសំណើសុំប្តឹងជំទាស់ចៅក្រម (sic) សមាជិក បួន(០៤)រូប នៃអង្គជំនុំជម្រះសាលាដំបូង មុននឹងបន្តចូលរួមនៅក្នុងសវនាការ។ គាត់ប្តឹងថា ចៅក្រមទាំងនេះបានជ្រើសរើសដូចដែលត្រូវបានអនុញ្ញាតយ៉ាងច្បាស់លាស់ នៅក្រោមវិធាន៣៤(៥) នៃវិធានផ្ទៃក្នុង ដើម្បីឲ្យបន្តចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ ដោយត្រូវនៅរង់ចាំសេចក្តីសម្រេចមួយលើសំណើសុំប្តឹងជំទាស់ចៅក្រមសិន។ ខៀវ សំផន បានស្វែងរកនូវការធ្វើសារណាបណ្តឹងសាទុក្ខលើសំណុំរឿង ០០២/០១ ឲ្យបានចប់សិន មុននឹងបន្តចូលរួមនៅក្នុងសវនាការ[3]។

---

[1] ពង្រៀងប្រតិចារឹក, ១៧ តុលា ២០១៤, នៅមុនជាប់នឹង 14:38:14។

[2] *ដដែលដូចមុន,* ត្រង់ 13:59:33 [នួន ជា៖ ខ្ញុំសូមណែនាំ និងស្នើសុំឲ្យមេធាវីរបស់ខ្ញុំឲ្យចេញពីបន្ទប់សវនាការ... ហើយនិងពហិការ [sic] មិនចូលរួមរាល់សវនាការនាពេលខាងមុខនៃសវនាការលើកទី២នេះ រហូតដល់បណ្តឹងជំទាស់ត្រូវបានសម្រេច]។ ត្រង់ 14:10:16 [ខៀវ សំផន៖ "មេធាវីខ្ញុំបានប្រាប់ខ្ញុំថា គាត់មិនអាចចំណាយពេលមកចូលរួមសវនាការផង ហើយរៀបចំសារណាបណ្តឹងឧទ្ធរណ៍ដ៏សំខាន់នេះ ឲ្យបានម៉ត់ចត់ផងទេ។ ដូច្នេះ ការសម្រេចរបស់ខ្ញុំតើត្រូវធ្វើយ៉ាងណានៅចំពោះសភាពការណ៍បែបនេះ?"] [សង្កត់ន័យបន្ថែមដោយ គូសបន្ទាត់ពីក្រោម]។

[3] *ដដែលដូចមុន,* ត្រង់ 14:11:53-14:17:31 [ខៀវ សំផន៖ "ខ្ញុំសូមជម្រាបលោកប្រធាននៅពេលណាដែលមេធាវីខ្ញុំ [*sic*] និងខ្ញុំរៀបចំសារណាឧទ្ធរណ៍បានចប់សព្វគ្រប់ ហើយយកទៅដាក់បានទាន់ពេលវេលា ព្រមទាំងនៅពេលណាដែលមេធាវីទាំងអស់គ្នា ខ្ញុំទាំងអស់គ្នាក៏ត្រឡប់មកចូលរួមសវនាការនេះវិញ"]។

៤. ស្ថានភាពបច្ចុប្បន្នគឺថាទាំង នួន ជា និងទាំង ខៀវ សំផន បានជ្រើសរើសក្រុមមេធាវីការពារក្ដីដ៏មានសមត្ថភាពដោយខ្លួនគាត់ ប៉ុន្តែបានណែនាំក្រុមមេធាវីការពារក្ដីរបស់ពួកគាត់ឱ្យបំពានលើសេចក្ដីបង្គាប់របស់តុលាការ និងមិនឱ្យចូលរួមនៅក្នុងសវនាការ។ ក្រុមមេធាវីការពារក្ដីទាំងនេះដែលត្រូវបានចាត់តាំងឱ្យទៅជនជាប់ចោទដោយ អ.វ.ត.ក បានបញ្ជាក់ថាពួកគាត់នឹងធ្វើតាមការណែនាំទាំងឡាយរបស់កូនក្ដីពួកគាត់ គឺបំពានលើសេចក្ដីបង្គាប់របស់តុលាការ និងរារាំងកិច្ចដំណើរការនីតិវិធីរហូតទាល់តែការទាមទាររបស់ពួកគាត់ត្រូវបានធ្វើតាម។ ដូច្នេះហើយបានជានៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤ ក្រុមមេធាវីការពារក្ដីខកខានមិនបានធ្វើតាមសេចក្ដីបង្គាប់ដ៏ជាក់លាក់មួយរបស់អង្គជំនុំជម្រះសាលាដំបូងឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការទេ[4]។

៥. បើសិនជាមិនបានដោះស្រាយទេ នោះការប្រកាសនៅនាទីចុងក្រោយរបស់ក្រុមមេធាវីការពារក្ដីដើម្បីធ្វើពហិការមិនចូលរួមសវនាការ មុខជានឹងរារាំងដល់សវនាការដែលបានចាត់នាពេលបច្ចុប្បន្ននេះ ដើម្បីចាប់ផ្ដើមដំណើរការស្ដាប់សក្ខីកម្មលើភស្តុតាង នៅថ្ងៃច័ន្ទទី២៧ ខែតុលា[5] នេះជាមិនខាន។ អំពើរបស់ពួកគាត់ចោទជាហានិភ័យមួយដ៏ធ្ងន់ធ្ងរក្នុងការពន្យារកិច្ចដំណើរការនីតិវិធី ហើយបើដូច្នេះនឹងមានការពន្យារដល់យុត្តិធម៌បន្ថែមទៀត និងមានការចំណាយលើអង្គជំនុំជម្រះនេះយ៉ាងច្រើនបន្ថែមទៀត។ ដោយឃើញថាសារៈសំខាន់នៃបញ្ហានេះ និងលទ្ធភាពពិតប្រាកដ ដែលស្ថានការណ៍បច្ចុប្បន្នអាចនឹងកើតឡើងច្រំដែលៗ នៅពេលណាមួយក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០២ បើករណីយុត្តិសាស្ត្រមួយត្រូវបានធ្វើឡើងដើម្បីជាការឱ្យរង្វាន់ដល់កលល្បិចបែបដូច្នេះនោះ ករណីយកិច្ចរបស់ក្រុមមេធាវីការពារក្ដី គឺដើម្បីការពារយ៉ាងស្វាហាប់នូវផលប្រយោជន៍របស់កូនក្ដីខ្លួន នៅក្នុងរង្វង់កាតព្វកិច្ចនៃវិធាននានារបស់អង្គជំនុំជម្រះ។ វាពុំមានវិធាននីតិវិធី ឬវិធានវិជ្ជាជីវៈណាមួយ ដែលគ្រាន់តែអនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដីបំពានលើសេចក្ដីបង្គាប់របស់តុលាការ ដោយធ្វើតាមការណែនាំទាំងឡាយរបស់កូនក្ដីខ្លួននោះទេ។ វាពុំមានតុលាការព្រហ្មទណ្ឌណាមួយដែលអាចដំណើរការបានដោយប្រសិទ្ធភាពទេ បើទុកឱ្យជនជាប់ចោទសម្រេចថាតើសេចក្ដីបង្គាប់ណាមួយរបស់តុលាការដែលក្រុមមេធាវីការពារក្ដីរបស់ពួកគេត្រូវគោរព ឬមិនត្រូវគោរពតាមនោះ។ សហព្រះរាជអាជ្ញាលើកស្នើឡើងថា គេត្រូវតែកំណត់ឱ្យបាននូវដំណោះស្រាយមួយ ដែលអនុញ្ញាតឱ្យសវនាការដំណើរការទៅមុខបានដោយពុំមានការផ្អាក។

៦. នៅក្នុងស្ថានភាពបច្ចុប្បន្ននេះ សហព្រះរាជអាជ្ញាសូមលើកស្នើឡើងថា ការចាត់ឱ្យមានក្រុមមេធាវីការពារក្ដីក្នុងឋានៈ*ជាមិត្តរបស់តុលាការ* ដោយអង្គជំនុំជម្រះ ដើម្បីជួយធានាដល់សិទ្ធិជាមូលដ្ឋាន

[4] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនគ្រប់ភាគីទាំងអស់, "កិច្ចប្រជុំរៀបចំសវនាការ, ២១ តុលា ២០១៤"។ ២០ តុលា ២០១៤ ["គ្រប់ភាគីទាំងអស់ត្រូវបានបង្គាប់ឱ្យចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ"]។

[5] អ៊ីមែលពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ផ្ញើជូនភាគីនានា, "ការកំណត់កាលវិភាគសម្រាប់សប្ដាហ៍ក្រោយ", ១៦ តុលា ២០១៤។

នៅក្នុងការទទួលបាននូវការជំនុំជម្រះក្តីមួយដ៏ត្រឹមត្រូវ នោះគឺជាដំណោះស្រាយមួយដែលនឹងអនុញ្ញាតឲ្យសវនាការដំណើរការទៅមុខបាន ហើយរឿងនោះគឺត្រូវគេបង្កើតឡើងបានយ៉ាងល្អប្រសើរនៅក្នុងការអនុវត្តកិច្ចដំណើរការនីតិវិធីជាអន្តរជាតិ។

៧. ដោយសារភាពបន្ទាន់នៃបញ្ហានេះ និងដោយសារការរង់ចាំការចាប់ផ្តើមសវនាការស្តាប់ភស្តុតាង សហព្រះរាជអាជ្ញាសូមស្នើឡើងថា សំណើនេះជាដំបូងត្រូវដាក់ជាភាសាអង់គ្លេសតែមួយសិន ដោយមានសំណៅជាភាសាខ្មែរតាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន[6]។

## II. **ច្បាប់ជាធរមាន**

៨. វិធាន២២(៤) នៃវិធានផ្ទៃក្នុង ចែងថា៖

> *នៅក្នុងការបំពេញការងាររបស់ខ្លួន មេធាវីត្រូវគោរពតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏ដូចជាច្បាប់ស្តីពីលក្ខន្តិកៈមេធាវីរបស់កម្ពុជា និងបទដ្ឋាន និងក្រមសីលធម៌វិជ្ជាជីវៈ ដែលបានទទួលស្គាល់។ ពួកគេមាន<u>កាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធិភាព និងត្រឹមត្រូវ</u>។*

៩. បទបញ្ជារដ្ឋបាលរបស់ផ្នែកគាំពារការការពារក្តី ("បទបញ្ជារបស់ DSS"), មាត្រា៧ ចែងថា៖

> *៧.១ អនុវត្តតាមដីការបស់អង្គជំនុំជម្រះវិសាមញ្ញ សហមេធាវី<u>ត្រូវការពាររឿងក្តីរហូតដល់ទីបញ្ចប់</u>។ ប្រសិនបើខកខាន អវត្តមានពីរឿងក្តីទោះបីជាមានការអនុញ្ញាតពីអង្គជំនុំជម្រះវិសាមញ្ញក៏ដោយ តែប្រាក់ឈ្នួលមួយផ្នែក ឬទាំងអស់អាចត្រូវរឹបអូស តាមការកំណត់របស់អង្គជំនុំជម្រះវិសាមញ្ញ។*

[6] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/២០០៧/១/វិសោធនកម្មលើកទី៨, ការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក, ៧ មីនា ២០១២, មាត្រា៨.៣។

១០. ក្រមសីលធម៌នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមរបស់ BAKC") ដែលបានធ្វើវិសោធនកម្មនៅឆ្នាំ២០១៣ បានចែងនៅក្នុងមាត្រា៣៧ និងមាត្រា៣៩ មួយផ្នែកថា៖

> ***មាត្រា៣៧.*** *មេធាវីត្រូវប្រកាន់ឲ្យបានខ្ជាប់ខ្ជួននូវឯករាជ្យភាព និងសេចក្ដីថ្លៃថ្នូរក្នុងវិជ្ជាជីវៈ នៅចំពោះមុខតុលាការ។ មេធាវីត្រូវគោរពតាមវិធាននីតិវិធី និងបទបញ្ជារបស់តុលាការ។ មេធាវីមិនត្រូវប្រើជាដាច់ខាតនូវវិធីមិនស្មោះត្រង់ ហើយត្រូវគោរពវិធីតទល់គ្នា។ មេធាវីមានសិទ្ធិសម្ដែងឡើងនូវអ្វីៗដែលខ្លួនយល់ថា មានប្រយោជន៍ដល់អតិថិជនរបស់ខ្លួន។*

> ***មាត្រា៣៩.*** *មេធាវីមិនត្រូវបង្កឲ្យមានការពន្យារនីតិវិធីតុលាការណាមួយ ដោយការធ្វេសប្រហែស ឬ មូលហេតុមិនសមហេតុផលដែលអាចប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌នោះឡើយ។*

១១. ក្រម *Code de déontologie des Avocats européens*, បានបង្រួមបញ្ចូលទៅក្នុង *Règlement* Intérieur *National de la Profession d'Avocat* (ប្រទេសបារាំង), មាត្រា២១.៤ ចែងថា៖

> *21.4.1 Déontologie de l'activité judiciaire: L'avocat qui comparaît devant les cours et tribunaux ou participe à une procédure doit observer les règles déontologiques applicables devant cette juridiction.*
>
> *21.4.2 Caractère contradictoire des débats: L'avocat doit en toute circonstance observer le caractère contradictoire des débats.*
>
> *21.4.3 Respect du juge: Tout en faisant preuve de respect et de loyauté envers l'office du juge, l'avocat défend son client avec conscience et sans crainte, sans tenir compte de ses propres intérêts ni de quelque conséquence que ce soit pour lui-même ou toute autre personne.*

១២. ជាចុងក្រោយ *វិធានស្ដីពីក្រមសីលធម៌មេធាវី* (ប្រទេសហូឡង់) ចែងថា៖

> [១.២ កិច្ចការ និង ការប្រព្រឹត្តរបស់មេធាវី]... *មេធាវីត្រូវដឹងថា របៀបរបបនៃការប្រព្រឹត្តរបស់ពួកគេ នឹងជួយកំណត់ ព្រមទាំងវិនិច្ឆ័យពីលក្ខណៈ (និងការបំពេញអាជីពរបស់ពួកគេ)។ មេធាវីត្រូវទប់ស្កាត់ទង្វើរទាំងឡាយណា ដែលនាំឲ្យខូចដល់ការជឿជាក់មកលើខ្លួន។ គោលបំណងរបស់មេធាវីម្នាក់ និងមេធាវីទូទៅ ត្រូវធ្វើយ៉ាងណាឲ្យទទួលបានការគោរព ក្នុងនាមជាអ្នកមានអាជីព*

*ពិតប្រាកដ ត្រូវធ្វើយ៉ាងណាឲ្យមតិរបស់ខ្លួនទទួលបានការគោរព និងជាទីទុកចិត្ត។ ឧទាហរណ៍ មេធាវីមិនត្រូវពឹងផ្អែកលើមធ្យោបាយណាដែលមិនត្រឹមត្រូវ ដូចជា ប្រកាស ឬចាត់វិធានការទាំងឡាយណាដែលមិនស្របនឹងគោលបំណងដែលមាននៅក្នុងចិត្តរបស់ពួកគេឡើយ។*

[វិធាន ១] *មេធាវី ត្រូវមានឥរិយាបថជាទីទុកចិត្តដល់អាជីពរបស់ខ្លួន ហើយដែលការអនុវត្តអាជីពផ្ទាល់ខ្លួននោះ មិនមានគ្រោះថ្នាក់ឡើយ។*

[វិធាន ៤] *មេធាវី ត្រូវមានការថែទាំឲ្យបានត្រឹមត្រូវ ចំពោះកិច្ចការទាំងឡាយណាដែលបានផ្ទុកផ្តាក់មកឲ្យខ្លួន។*

[វិធាន ៩(១)] *មេធាវី ត្រូវមាន<u>ការទទួលខុសត្រូវទាំងស្រុង ក្នុងការកាន់កាប់សំណុំរឿង</u>។ មេធាវី <u>មិនអាចគេចវេះពីការទទួលខុសត្រូវនេះ តាមរយៈការទទួចឲ្យមានការណែនាំ ដើម្បីទទួលបានពីកូនក្តីរបស់ខ្លួនឡើយ</u>។ យ៉ាងណាមុញ្ញ ពួកគេមិនត្រូវធ្វើអំពើណាមួយដែលប្រឆាំងនឹងគោលបំណងជាក់ស្តែងរបស់កូនក្តីឡើយ។*

## III. អំណះអំណាង

### ក. ការណែនាំរបស់កូនក្តីមិនឲ្យមេធាវីចូលរួមសវនាការ តម្រូវឲ្យមានវិធានការដោះស្រាយដើម្បីធានាចំពោះកិច្ចដំណើរការនីតិវិធីឲ្យមានប្រសិទ្ធភាព និងមានការពេញលេញ

១៣. មេធាវីនៅចំពោះមុខ អ.វ.ត.ក មិនត្រឹមតែមានភារកិច្ចចំពោះកូនក្តីរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានកាតព្វកិច្ចចំពោះអង្គជំនុំជម្រះសាលាដំបូង "ក្នុងការលើកស្ទួយយុត្តិធម៌ និងការប្រព្រឹត្តទៅនៃកិច្ចដំណើរការនីតិវិធីដោយត្រឹមត្រូវ និងមានប្រសិទ្ធភាព" ស្របតាមវិធាន២២(៤) នៃវិធានផ្ទៃក្នុងផងដែរ។ ចំណុចនេះឆ្លុះបញ្ចាំងទៅលើវិធាននីតិវិធីអន្តរជាតិ ដែលគេបានបង្កើតឡើងនៅក្នុងចំណោមតុលាការព្រហ្មទណ្ឌអន្តរជាតិនានា។ នៅក្នុងរឿងក្តី *Barayagwiza* មេធាវីការពារក្តីបានស្វែងរកការដកខ្លួនចេញពីរឿងក្តីដែលកំពុងតែដំណើរការ ដោយផ្អែកលើការណែនាំជាបន្ទាន់របស់កូនក្តីខ្លួន "មិនឲ្យធ្វើជាតំណាងរបស់គាត់នៅក្នុងសាលសវនាការ"[7]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR បានច្រានចោលសំណើនេះដោយបានកត់សំគាល់ថា មេធាវីដែលបានចាត់តាំងនៅ ICTR មានកាតព្វកិច្ចមិនត្រឹមតែចំពោះកូនក្តីខ្លួនប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានភារកិច្ចចំពោះអង្គជំនុំជម្រះផងដែរ ដើម្បីធានាថា ជនជាប់ចោទទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ[8]។

---

[7] *រដ្ឋអាជ្ញា ទល់នឹង Barayagwiza*, សំណុំរឿងលេខៈ ICTR-97-19-T, សេចក្តីសម្រេចលើញត្តិស្នើសុំដកខ្លួនចេញរបស់មេធាវីការពារក្តី (អង្គជំនុំជម្រះសាលាដំបូង I), ២ វិច្ឆិកា ២០០០ ត្រង់កថាខណ្ឌ១៧។

[8] *ដដែលដូចខាងលើ*, ត្រង់កថាខណ្ឌ២១។

១៤. មេធាវីការពារក្តី ខៀវ សំផន និង នួន ជា មានកាតព្វកិច្ច “អនុវត្តរឿងក្តីរហូតដល់ចប់”។ បើតាមការប្រព្រឹត្តរបស់ពួកគាត់នាពេលថ្មីៗនេះ ពួកគេមិនត្រឹមតែប្រមាថដីកាសម្រេចរបស់អង្គជំនុំជម្រះប៉ុណ្ណោះទេ ដែលអំពើតែមួយនេះជាការគ្រប់គ្រាន់សម្រាប់ការដាក់ទណ្ឌកម្មក៏ដោយ ប៉ុន្តែថែមទាំងរំលោភលើក្រមសីលធម៌របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៀតផង ដែលពួកគាត់ទាំងអស់ត្រូវតែឆ្លើយតប ហើយដែលតម្រូវឱ្យមេធាវី “គោរពតាមប្បញ្ញត្តិនីតិវិធី និងបទបញ្ជាផ្ទៃក្នុងរបស់តុលាការ” “គោរពតាមអភិក្រមដេញដោល” និង “មិនត្រូវបង្កឱ្យមានការពន្យារពេលដល់កិច្ចដំណើរការនីតិវិធីណាមួយរបស់តុលាការ ដោយសារការធ្វេសប្រហែស ឬមូលហេតុមិនស្របផ្សេងៗទៀតដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌”នោះឡើយ។ មេធាវីអន្តរជាតិក៏ហាក់បីជាមានការរំលោភលើក្រមសីលធម៌មេធាវីរបស់ប្រទេសរៀងៗខ្លួនផងដែរ។

១៥. ដូចរឿងក្តី *Barayagwiza* ដែរ នួន ជា និង ខៀវ សំផន សុទ្ធតែមានមេធាវីតាមការជ្រើសរើសរបស់ខ្លួន ហើយមិនដែលត្អូញត្អែរពីការធ្វើតំណាងរបស់ពួកគេទេ។ ទាក់ទិនរឿងក្តី *Barayagwiza,* ចៅក្រម Gunawardana បានហៅការណែនាំរបស់ Barayagwiza ចំពោះមេធាវីរបស់ខ្លួនមិនឱ្យចូលរួមសវនាការថាជា “ទម្រង់មួយនៃការតវ៉ា” និងបានកត់សំគាល់ថា “គាត់មិនមែនមិនពេញចិត្តនឹងការប្រព្រឹត្ត ឬសមត្ថភាពរបស់មេធាវីរបស់គាត់ទេ តាមពិតគាត់មានទំនុកចិត្តពេញលេញចំពោះពួកគេ”[9]។ ការអនុវត្តក៏ដូចគ្នានៅទីនេះដែរ ដូចដែលកំណត់សំគាល់ផ្ទាល់មាត់របស់ នួន ជា និង ខៀវ សំផន បានធ្វើកាលពីថ្ងៃទី១៧ ខែតុលាការ ឆ្នាំ២០១៤ បញ្ជាក់យ៉ាងច្បាស់ថាពួកគាត់មិនមែនមិនពេញចិត្តនឹងមេធាវីរបស់ពួកគាត់នោះឡើយ។ ក្នុងកាលៈទេសៈទាំងនេះ ចៅក្រម Gunawardana គួរបានចាត់តាំងមេធាវីប្រចាំការឱ្យធ្វើជា*មេធាវីជាមិត្តតុលាការ* និងដើម្បីតំណាងឱ្យផលប្រយោជន៍របស់ជនជាប់ចោទនៅក្នុងតុលាការនៅពេលណាចាំបាច់។ គាត់បានធ្វើការកត់សំគាល់ទៅលើអំណាចផ្លូវច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចាត់តាំងមេធាវី “ពេលណាផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យ” និងអំណាចជាប់មកជាមួយក្នុងការ “គ្រប់គ្រងកិច្ចដំណើរការនីតិវិធីរបស់ខ្លួនផ្ទាល់”[10]។ អភិក្រមដែលផ្តោតទៅរកដំណោះស្រាយរបស់ចៅក្រម Gunawardana នេះ គឺជាការអនុវត្តដែលមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិនានា[11] ព្រមទាំងនៅកម្ពុជា[12] និងបណ្តាយុត្តាធិការប្រទេសដទៃ

---

[9] *ដដែលដូចខាងលើ។ មតិស្រប និងមតិដាច់ដោយឡែករបស់ចៅក្រម Gunawardana* [ទំព័រ និងកថាខណ្ឌ គ្មានលេខ]។

[10] *ដដែលដូចខាងលើ។ មតិស្រប និងមតិដាច់ដោយឡែករបស់ចៅក្រម Gunawardana* [ទំព័រ និងកថាខណ្ឌ គ្មានលេខ]។

[11] *រដ្ឋអាជ្ញា ទល់នឹង Vojislav Šešelj,* សំណុំរឿងលេខ: IT-03-67-PT, សេចក្តីសម្រេចលើញត្តិរបស់រដ្ឋអាជ្ញា ស្នើសុំការសម្រេចចាត់តាំងមេធាវីឱ្យជួយក្នុងការការពារក្តីឱ្យ Vojislav Šešelj (អង្គជំនុំជម្រះសាលាដំបូង II), ៩ ឧសភា ២០០៣ (“សេចក្តីសម្រេចរបស់ *Šešelj”*)។

[12] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា៣០១។

ទៀត[13] ហើយក៏ស្របគ្នាទាំងស្រុងជាមួយនឹងភារកិច្ចរបស់អង្គជំនុំជម្រះ ក្នុងការធានាចំពោះកិច្ចដំណើរការនីតិវិធីឲ្យមានប្រសិទ្ធិភាព និងឆាប់រហ័ស។

## ខ. ការចាត់តាំងមេធាវី *ជាមិត្តរបស់តុលាការ* អាចអនុញ្ញាតបានដើម្បីផលប្រយោជន៍យុត្តិធម៌ ក្នុងការធានាចំពោះសិទ្ធិជាមូលដ្ឋាននៃការជំនុំជម្រះដោយត្រឹមត្រូវ

១៦. ប្រសិនបើកូនក្តីម្នាក់ណែនាំឲ្យមេធាវីរបស់ខ្លួន អវត្តមានពីកិច្ចដំណើរការនីតិវិធីរបស់តុលាការដែលជាការរំលោភកាតព្វកិច្ចរបស់ខ្លួនចំពោះអង្គជំនុំជម្រះ សូម្បីតែក្នុងរយៈពេលមានកំណត់ណាមួយក៏ដោយ គឺគាត់កំពុងតែបង្កឲ្យមានការបង្អាក់កិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងកាលៈទេសៈដូចនេះ អង្គជំនុំជម្រះមានអំណាចស្របតាមគោលការណ៍ជាមូលដ្ឋាននៃវិធាន ២១ ដើម្បីធានាឲ្យប្រាកដថា សវនាការប្រព្រឹត្តទៅ "ដោយត្រឹមត្រូវ និងមានការដេញដោលគ្នា" មានប្រសិទ្ធិភាពឆាប់រហ័ស និង "បញ្ចប់ក្នុងពេលវេលាសមស្រប"។ ច្បាប់កម្ពុជាចាត់ទុក "ជំនួយរបស់មេធាវី" នៅពេលសវនាការ "គឺជាការចាប់បង្ខំ" បើសិនជារឿងក្តីនោះជាបទល្មើសឧក្រិដ្ឋ[14] ដូចក្នុងរឿងក្តីនៅពេលនេះ។ អង្គជំនុំជម្រះក៏មានអំណាចស្វែងរកការណែនាំនៅក្នុងស្ថាប័នយុត្តិសាស្ត្រអន្តរជាតិដែលស្របគ្នា ពាក់ព័ន្ធនឹងដំណោះស្រាយនៃការរំខាន ការបង្អាក់ និងការពន្យារពេលដោយសារតែការធ្វើស្វ័យតំណាងរបស់ជនជាប់ចោទ[15]។ សិទ្ធិរបស់កូនក្តីម្នាក់ក្នុងការណែនាំមេធាវី និងរៀបចំកិច្ចការពារតាមឆន្ទៈរបស់គាត់ មិនមែនសំខាន់តិចជាងសិទ្ធិស្វ័យការពាររបស់គាត់ឡើយ។ យ៉ាងណាមិញ គ្មានសិទ្ធិណាមួយដាច់ខាតទេ។ ក្នុងរឿងក្តី *Stanković* អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា៖

[13] *McKaskle ទល់នឹង Wiggins* 465 US 168 (1984) (តុលាការកំពូលសហរដ្ឋអាមេរិក); ក្រម Code de Procédure Pénale (ប្រទេសបារាំង), មាត្រា២៧៤, ៣១៧។ *Strafprozeßordnung* (ប្រទេសអាល្លឺម៉ង់), s. 140។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević*, សំណុំរឿងលេខៈ IT-02-54-T, សំអាងហេតុសម្រាប់សេចក្តីសម្រេចលើញត្តិស្នើសុំរបស់អយ្យការ ពាក់ព័ន្ធនឹងការចាត់តាំងមេធាវី (អង្គជំនុំជម្រះសាលាដំបូង II), ៤ មេសា ២០០៣ ត្រង់កថាខណ្ឌ៤៩ ("សេចក្តីសម្រេចរបស់ *Milošević*")។

[14] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, មាត្រា៣០១(១)។

[15] *រដ្ឋអាជ្ញា ទល់នឹង Goran Janković និង Radovan Stanković*, សំណុំរឿងលេខៈ IT-96-23/2-PT, សេចក្តីសម្រេចបន្ទាប់ពីមានការជូនដំណឹងរបស់អ្នកគ្រប់គ្រងបញ្ជីអំពីសំណើរបស់ Radovan Stanković សុំធ្វើតំណាងដោយខ្លួនឯង(ស្វ័យតំណាង)។ (អង្គជំនុំជម្រះសាលាដំបូង I), ១៩ សីហា ២០០៥ ("សេចក្តីសម្រេចរបស់ *Stanković*); *រដ្ឋអាជ្ញា ទល់នឹង Sam Hinga Norman និងគូកន.*, សំណុំរឿងលេខៈ SCSL-2004-14-T, សេចក្តីសម្រេចលើពាក្យសុំរបស់ Samuel Hinga Norman សុំធ្វើតំណាងដោយខ្លួនឯង ស្របតាមមាត្រា១៧(៤)(ឃ) នៃលក្ខន្តិកៈរបស់តុលាការពិសេស (អង្គជំនុំជម្រះសាលាដំបូង), ៨ មិថុនា ២០០៤ ("សេចក្តីសម្រេចរបស់ *Norman*)។ សេចក្តីសម្រេចរបស់ *Milošević*, កំណត់សំគាល់ខាងដើម លេខ១៣។ សេចក្តីសម្រេចរបស់ *Šešelj* Decision, កំណត់សំគាល់ខាងដើម លេខ១១។

> [...] *តុលាការនេះ និងតុលាការអន្តរជាតិដទៃទៀត បានសម្រេចស្របគ្នាថា អាចមាន កាលៈទេសៈសមស្របនានា ហើយ<u>អង្គជំនុំជម្រះមានសមត្ថកិច្ចដើម្បីទទួចថា ការការពារខ្លួន ត្រូវតែធ្វើឡើងដោយមេធាវី</u>... ដើម្បីធានាថាការប្រើប្រាស់នូវសិទ្ធិស្វ័យតំណាងមិនមាន អានុភាពបង្អាក់ដល់ការប្រព្រឹត្តទៅរបស់សវនាការដោយត្រឹមត្រូវឡើយ*[16] ។

១៧. នៅក្នុងករណីរឿងក្តីរបស់ *Norman* បើសិនជាជនជាប់ចោទបានស្វែងរកសុំធ្វើជាតំណាងដោយខ្លួនឯងនោះ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ថា "សិទ្ធិដែលមានគុណវុឌ្ឍិ"របស់គាត់ក្នុងការធ្វើតំណាងដោយខ្លួនឯង "អាចឱ្យអនុវត្តបាន លុះត្រាតែនៅក្នុងករណីមានជំនួយពីមេធាវីដែលត្រូវបានចាត់តាំងសំរាប់សវនាការជំនុំជម្រះក្តីប៉ុណ្ណោះ"[17]។ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការពិសេសសំរាប់ប្រទេសសៀរ៉ាឡេអូន(SCSL) បានផ្អែកសេចក្តីសម្រេចរបស់ខ្លួន លើមូលដ្ឋាននៃ "បញ្ហាសំខាន់ៗ"មួយចំនួនដែលអាចអនុវត្តបានដូចគ្នាសំរាប់កិច្ចដំណើរការសវនាការនៅក្នុងសំណុំរឿង០០២/០២៖

> [...](*ii*) *សិទ្ធិត្រូវមានមេធាវីការពារក្តី ជួយធ្វើឱ្យធូរស្រាលដល់អង្គចៅក្រមជំនុំជម្រះពីបន្ទុកក្នុងការត្រូវពន្យល់ និងពង្រឹងការអនុវត្តនូវវិធានជាមូលដ្ឋាននានានៃពីធីសារសំរាប់សវនាការ និងក្នុងការជួយដល់ជនជាប់ចោទក្នុងការពុះពារនូវឧបសគ្គនានាដែលមានជាទម្លាប់ និងខាងអង្គច្បាប់ដែលជនជាប់ចោទអាចជួបប្រទះ ក្នុងករណីបើគាត់ធ្វើតំណាងឱ្យខ្លួនឯងព្រោះ ដោយហេតុថា តាមស្មារតីរបស់យើង តុលាការត្រូវបានសន្មតថាស្ថិតក្នុងបរិបទដែលគូរក្តីតទល់គ្នា ដែលត្រូវស្ថិតនៅជាអាជ្ញាកណ្តាល ហើយមិនមែនជាអ្នកចូលរួមដើម្បីចាត់វិធានការត្រៀមទុកជាមុន នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនោះទេ។ (iii) <u>ដោយសារតែលក្ខណៈស្មុគស្មាញនៃករណីរឿងក្តីបច្ចុប្បន្ននេះ គេមិនអាចបដិសេធបានទេថា ការជំនុំជម្រះក្តីរួមគ្នានៃទំហំដ៏ធំបែបនេះ ដោយបានយកចិត្តទុកដាក់ទៅលើស្ថានទម្ងន់នៃបទល្មើស និងដោយបានគិតគូរពិចារណាទៅលើចំនួននៃសាក្សីនានាដែលអយ្យការ និងមេធាវីការពារក្តីត្រូវកោះហៅដែលធ្វើឡើង សម្រាប់សវនាការមួយដែលមានលក្ខណៈស្មុគស្មាញ និងភាពសាំញ៉ាំដែលមានសក្តានុពលខ្ពស់នៃការវិវឌ្ឍន៍ជាតួយ៉ាងនៃច្បាប់អន្តរជាតិ។ (iv) ហើយការបំពេញឱ្យបានចប់សព្វគ្រប់នូវសវនាការជំនុំជម្រះក្តីដោយឆាប់រហ័ស ក៏វាមានផលប្រយោជន៍ជាសាធារណៈដល់ជាតិ និងអន្តរជាតិផងដែរ។ (v)</u> ជាងនេះទៅទៀត មានសក្តានុពលខ្ពស់ ដែលធ្វើឱ្យអាក់ខានជាបន្តទៅទៀត*

---

[16] *ដដែលដូចខាងលើ*។ សេចក្តីសម្រេចរបស់ *Stanković* ត្រង់កថាខណ្ឌ១០។

[17] សេចក្តីសំរេចលើករណីរឿងក្តីរបស់ *Norman*, កំណត់សំគាល់លេខ១៥ *ខាងលើ* ត្រង់កថាខណ្ឌទី៣២។

*ដល់កាលវិភាគ និងប្រតិទិនរបស់តុលាការ ដូចដែលយើងធ្លាប់បានធ្វើជាសាក្សីរួចហើយចំពោះករណីនេះ*[18] ។

១៨. សហព្រះរាជអាជ្ញា សូមលើកឡើងជាមតិថា ក្នុងស្ថានភាពបច្ចុប្បន្ន ដើម្បីជាផលប្រយោជន៍ដល់ភាពត្រឹមត្រូវ និងយុត្តិធម៌ និងដើម្បីឲ្យសវនាការជំនុំជម្រះក្តីបានឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូង គួរតែចាត់តាំងមេធាវីការពារក្តី ដើម្បីឲ្យដើរតួជា *មិត្តរបស់តុលាការ (amici curiae)* ឲ្យ ខៀវ សំផន និង នួន ជា រហូតទល់នឹងពេលដែលមេធាវីការពារក្តីខកខានមិនបានធ្វើជាតំណាងដោយយកចិត្តទុកដាក់ឲ្យបានម៉ត់ចត់ឲ្យផលប្រយោជន៍របស់ពួកគេ នៅក្នុងការជំនុំជម្រះក្តី នាពេលបច្ចុប្បន្ន។ ការធ្វើឲ្យខូចប្រយោជន៍ណាមួយដែលបានបណ្តាលមកពីការដាក់ជំនួសនេះ មិនអាចត្រូវបានចាត់ទុកថា ជាការមិនត្រឹមត្រូវចំពោះជនជាប់ចោទ ឬថាជាការរំលោភបំពានសិទ្ធិដែលត្រូវមានមេធាវីនោះឡើយ ព្រោះដោយហេតុថា ស្ថានការណ៍ត្រូវបានបង្កើតឡើងដោយជនជាប់ចោទខ្លួនឯងផ្ទាល់។ តុលាការបានគោរពចំពោះសិទ្ធិត្រូវមានមេធាវីការពារក្តី និងបានផ្តល់ឲ្យ និងបានចេញចំណាយសំរាប់ក្រុមមេធាវីការពារក្តីនានាដែលបានជ្រើសយកដោយ នួន ជា និង ខៀវ សំផន ក៏ប៉ុន្តែជនជាប់ចោទទាំងនេះបានណែនាំឲ្យក្រុមមេធាវីការពារក្តីរបស់ខ្លួន ធ្វើពហិការមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការទៅវិញ។

១៩. លើសពីនេះ សហព្រះរាជអាជ្ញាថែមទាំងបានធ្វើការកត់សំគាល់ថា ការចាត់តាំង *មិត្តរបស់តុលាការ (amici curiae)* រាប់បញ្ចូលទាំងអ្នកទាំងឡាយដែលដើរតួជាអ្នកជំនួយការឲ្យមេធាវីការពារក្តីផង នឹងត្រូវស្ថិតនៅក្នុងអំណាចដែលមានជាប់មកជាមួយស្រាប់របស់អង្គជំនុំជម្រះសាលាដំបូងដោយផ្ទាល់ ក្នុងការធ្វើបទបញ្ញាផ្សេងសំរាប់វិធីដំណើរការរបស់ខ្លួន និងធានាឲ្យប្រាកដថា ការជំនុំជម្រះក្តីបានប្រកបដោយភាពត្រឹមត្រូវ និងឆាប់រហ័ស។ តួនាទីរបស់អង្គភាពគាំពារការការពារក្តី (DSS) គួរតែដើម្បីផ្តល់នូវបញ្ជីមេធាវីការពារក្តីដែលមានគុណវុឌ្ឍិ និងដែលអាចឲ្យអង្គជំនុំជម្រះ ងាយរកបាន។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានធ្វើការបញ្ជាក់បំភ្លឺ នៅក្នុងករណីរឿងក្តីរបស់ *Karadžić* ថា៖

> *[…] ការតែងតាំងមេធាវីប្រចាំការ( standby counsel)*<u>*មិនមែនជាកម្មវត្ថុសំរាប់នីតិវិធីដែលធ្វើឲ្យស្របតាមទម្រង់ការជាងនេះ ដែលត្រូវបានរៀបចំឡើង ដើម្បីធ្វើនិយ័តកម្មដល់ការចាត់តាំងមេធាវីការពារក្តីសំរាប់ជនសង្ស័យ ឬជនជាប់ចោទទាំងឡាយដែលទន់ខ្សោយដែលមិនជ្រើសយកការធ្វើជាតំណាងដោយខ្លួនឯង។ ក្នុងការចាត់តាំងមេធាវីប្រចាំការ( standby counsel) ក្រឡាបញ្ជីនាយក ឬអង្គជំនុំជម្រះណាមួយ អាចលើក*</u>

[18] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២៦ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។

*យោងទៅលើនីតិវិធីនានាដែលធ្លាប់បានប្រើនៅក្នុងការចាត់តាំងមេធាវី ក្នុងបរិបទផ្សេងទៀត តែមិនមែនតម្រូវនោះទេ*[19] ។

២០. ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសំរេចនៅក្នុងករណីរឿងក្តីរបស់ *Milošević* នៅពេលធ្វើដីកាសំរេចមួយស្រដៀងគ្នានេះ *មេធាវីជាមិត្តរបស់តុលាការ (amici curiae* counsel) មិនគួរ "ធ្វើជាតំណាងឱ្យជនជាប់ចោទនោះទេ ប៉ុន្តែ [...] ជួយនៅក្នុងការធ្វើការសំរេចចិត្តឱ្យបានត្រឹមត្រូវលើករណីរឿងក្តី"[20] ដោយជួយដល់អង្គជំនុំជម្រះក្នុងការថែរក្សាការពារនូវភាពត្រឹមត្រូវ និងសុច្ចរិតភាពនៃកិច្ចដំណើរការនីតិវិធីរឿងក្តី នៅក្នុងពេលដែលមេធាវីការពារក្តីបន្តបដិសេធមិនព្រមចូលរួមនៅក្នុងសវនាការជំនុំជម្រះក្តី។ ហេតុដូចនេះ អង្គជំនុំជម្រះអាចតែងតាំង*មេធាវីជាមិត្តរបស់តុលាការ (amici curiae* counsel) បែបដូចនេះ ជាបន្ទាន់ ដោយមិនចាំបាច់ពន្យារពេលសវនាការប្រយោជន៍ដើម្បីត្រៀមរៀបចំបំពេញមុខងាររបស់ខ្លួន(ដូចដែលមេធាវីណាម្នាក់ត្រូវធ្វើនៅក្នុងពេលតែងតាំងជាអចិន្ត្រៃយ៍ដើម្បីឱ្យជំនួសមេធាវីដែលមានស្រាប់)។ សហព្រះរាជអាជ្ញាសូមជូនជាមតិថា គ្មានមូលហេតុទាល់តែសោះថា ការប្រាស្រ័យទាក់ទងគ្នាពីដំបូងពីអង្គភាពគាំពារការពារក្តី(DSS) និងការដាក់ជូននូវបញ្ជីឈ្មោះមេធាវី ដែលមានគុណវុឌ្ឍិ និងដែលអាចងាយរកបានពីអង្គភាពគាំពារការពារក្តី ទៅអង្គជំនុំជម្រះ នឹងត្រូវធ្វើលើសពីប៉ុន្មានថ្ងៃតែប៉ុណ្ណោះ។ តាមបទពិសោធន៍កន្លងមកនៅក្នុងតុលាការនេះ និងនៅតុលាការអន្តរជាតិផ្សេងទៀត បានបង្ហាញថាពុំមានការលំបាកក្នុងការរកមេធាវីដែលមានស្រាប់ក្នុងស្រុក ឬដែលត្រៀមរៀបចំដើម្បីធ្វើដំណើរមកកាន់តុលាការនេះ តាមការជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតនោះទេ។

២១. ហេតុដូចនេះ សហព្រះរាជអាជ្ញាសូមសង្កត់ធ្ងន់ថា មេធាវីការពារក្តីបានដណ្តើមមុខងាររបស់អង្គជំនុំជម្រះ ហើយធ្វើឱ្យខូចដល់សិទ្ធិរបស់ភាគីផ្សេងទៀត ករណីបើសិនជាពួកគេកំណត់ថាតើពេលណាត្រូវចាប់ផ្តើម ឬត្រូវឈប់នោះ។ ការតែងតាំង *មេធាវីជាមិត្តរបស់តុលាការ (amici curiae* counsel) គឺជាវិធានការបណ្តោះអាសន្នមួយ ដែលអនុញ្ញាតឱ្យសវនាការជំនុំជម្រះក្តីអាចបន្តធ្វើដោយពុំមានការអាក់ខាន ដែលហេតុនេះជាសំខាន់បំផុត មេធាវីដូចខាងលើនេះគួរតែត្រូវបានតែងតាំងជាបន្ទាន់។

---

[19] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Radovan Karadžić,* សំណុំរឿងលេខ IT-95-5/18-AR73.6, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍របស់ Radovan Karadžić ពីសេចក្តីសំរេចលើញត្តិស្នើសុំឱ្យទុកនៅទំនេរនូវការតែងតាំង Richard Harvey (អង្គជំនុំជម្រះសាលាឧទ្ធរណ៍), ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ត្រង់កថាខណ្ឌទី៣៥ [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។

[20] *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Slobodan Milošević,* សំណុំរឿងលេខ IT-02-54-T, ដីកាស្នើអញ្ជើញឱ្យចាត់តាំង *មិត្តរបស់តុលាការ Amicus Curiae* (អង្គជំនុំជម្រះសាលាដំបូងទីពីរ), ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

២២. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងណែនាំដល់អង្គភាពគាំពារការពារក្តី(DSS) ឲ្យធ្វើទំនាក់ទំនងជាបន្ទាន់ទៅអ្នកទាំងឡាយដែលមានឈ្មោះនៅក្នុងបញ្ជីមេធាវីជាតិ និងបញ្ជីមេធាវីអន្តរជាតិ-ដែលនៅក្នុងពេលបច្ចុប្បន្ននេះមិនមានជាប់រវល់នៅក្នុងបញ្ហាផ្សេងទៀតនៅចំពោះមុខ អវតក ឬម្យ៉ាងទៀត មិនកំពុងប្រឈមមុខនឹងទំនាស់ផលប្រយោជន៍ដែលមានសក្តានុពល-ដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា តើមានមេធាវីណាខ្លះដែលមានបំណង និងនៅទំនេរអាចមកដើរតួនាទីជា *មិត្តរបស់តុលាការ (amici curiae)*បាន រហូតទល់ពេលប៉ុន្មានខែជាបន្ទាប់ទៅទៀតនេះ ហើយរាយការណ៍ឈ្មោះមេធាវីទាំងនោះជាសម្ងាត់ មកអង្គជំនុំជម្រះសាលាដំបូង។

## IV. **ដំណោះស្រាយដែលបានស្នើសុំ**

២៣. អាស្រ័យមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពជូនជាអនុសាសន៍ ដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាៈ

ក. **ចេញដីកាបង្គាប់**ឲ្យមេធាវីរបស់ នួន ជា និង ខៀវ សំផន បន្តធ្វើជាតំណាងឲ្យកូនក្តីរបស់ខ្លួនតទៅទៀត នៅក្នុងគ្រប់កិច្ចដំណើរការនីតិវិធីសវនាការជំនុំជម្រះក្តីទាំងអស់ និងឲ្យចូលរួមនៅក្នុងគ្រប់សវនាការជំនុំជម្រះ និង គ្រប់កិច្ចប្រជុំដើម្បីរៀបចំសវនាការទាំងអស់។

ខ. **ព្រមាន**ដល់មេធាវីការពារក្តីរបស់ នួន ជា និង ខៀវ សំផន ថា បើមានការខកខានណាមួយតទៅទៀតក្នុងការចូលរួមនៅក្នុងសវនាការរបស់តុលាការ ចាកចេញដោយពុំមានការអនុញ្ញាត ឬខកខានមិនបានតំណាងឲ្យកូនក្តីរបស់ពួកខ្លួនឲ្យអស់ពីសមត្ថភាពខាងវិជ្ជាជីវៈរបស់ខ្លួននៅក្នុងគ្រប់ដំណើរការនីតិវិធីទាំងអស់ នឹងត្រូវបានចាត់ទុកថាជាការធ្វើឲ្យរាំងស្ទះដល់ដំណើរការនីតិវិធី តាមវិធាន៣៨ នៃវិធានផ្ទៃក្នុង ដែលអង្គជំនុំជម្រះនឹងដាក់ទណ្ឌកម្មសមស្រប។

គ. **ចេញដីកាបង្គាប់**ឲ្យប្រធានអង្គភាពគាំពារការពារក្តី ឲ្យរាយការណ៍ជាសម្ងាត់ជូនអង្គជំនុំជម្រះតែប៉ុណ្ណោះ ស្តីពីភាពនៅទំនេរនៃមេធាវីចំនួនពីរនាក់ (ម្នាក់សំរាប់ជនជាប់ចោទម្នាក់)ជាតិ ឬអន្តរជាតិ ដើម្បីឲ្យដើរតួនាទីជា*មិត្តរបស់តុលាការ (amici curiae )* របស់

អង្គជំនុំជម្រះ ដើម្បីការពារសិទ្ធិជាមូលដ្ឋានក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយត្រឹមត្រូវក្នុងសំណុំរឿង០០២/០២ សំរាប់រយៈពេលដែលនៅសល់នៃឆ្នាំ២០១៤។

ឃ. **ណែនាំ**ទាំងជនជាប់ចោទ និងទាំងមេធាវីការពារក្តីរបស់ពួកគេថា បើសិនជាមេធាវីការពារក្តីខកខានមិនបានចូលរួមនៅក្នុងសវនាការណាមួយ អង្គជំនុំជម្រះនឹងចាត់តាំងមេធាវីម្នាក់ឱ្យធ្វើជា*មិត្តរបស់តុលាការ* (*amici curiae* ) ដោយឱ្យទទួលខុសត្រូវដើម្បីការពារសិទ្ធិជាមូលដ្ឋាន ក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវរបស់ជនជាប់ចោទ រហូតដល់ពេលណាមួយ ដែលមេធាវីរបស់ជនជាប់ចោទវិលត្រឡប់មកចូលរួមនៅក្នុងដំណើរការនីតិវិធីវិញ ឬរហូតដល់ពេលដែលមេធាវីត្រូវបានហាមឃាត់លែងឱ្យចូលមកបង្ហាញខ្លួនជួសមុខឱ្យជនជាប់ចោទដោយសារមូលហេតុប្រព្រឹត្តអំពើខុសឆ្គងជាបន្តបន្ទាប់៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |